Khmer/ ខ្មែរ

## គោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ប្រព័ន្ធ
## Catholic Health Initiatives

នៅ CHI ការបង្កើតសហគមន៍ដែលកាន់តែមានសុខភាពល្អ និងការតស៊ូមតិគាំទ្រសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះគឺជាបេសកកម្មរបស់យើងផង និងជាចំណង់របស់យើង។ វិធីមួយដែលយើងធ្វើរឿងនេះបាន គឺតាមរយៈកម្មវិធីជំនួយហិរញ្ញវត្ថុ CHI របស់យើង ដែលក្នុងនោះយើងកាត់បន្ថយតម្លៃចំណាយនៃវិក្កយបត្រវេជ្ជសាស្ត្ររបស់អ្នកជំងឺផ្អែកលើតម្រូវការហិរញ្ញវត្ថុរបស់ពួកគេ។

### របៀបដែលយើងអាចជួយបាន
យើងផ្តល់ការថែទាំដោយឥតគិតថ្លៃសម្រាប់សេវាកម្មសង្គ្រោះបន្ទាន់ ឬសេវាកម្មដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រដទៃផ្សេងទៀតសម្រាប់អ្នកជំងឺរបស់យើងដែលមាន៖

- ប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំដែលតិចជាង ឬស្មើនឹង 300% នៃកម្រិតភាពក្រីក្ររបស់សហព័ន្ធ ដូចដែលត្រូវបានកំណត់ដោយគោលការណ៍ណែនាំដែលចេញផ្សាយជាប្រចាំឆ្នាំដោយក្រសួងសុខាភិបាល និងសេវាកម្មមនុស្សសហរដ្ឋអាមេរិក (FPL)។ តំណទៅកាន់គោលការណ៍ណែនាំ៖ https://aspe.hhs.gov/poverty-guidelines
- បានសហប្រតិបត្តិការប្រកបដោយការប្រឹងប្រែងដើម្បីប្រើឲ្យអស់ជម្រើសនៃការទូទាត់ដទៃទៀតទាំងអស់ និង
- បានបំពេញពាក្យសុំកម្មវិធី ហើយបានផ្តល់ឯកសារគាំទ្រដើម្បីផ្ទៀងផ្ទាត់ប្រាក់ចំណូល។

កំណត់សម្គាល់៖ ក្នុងករណីខ្លះ អ្នកជំងឺអាចនឹងត្រូវបានផ្តល់ជូននូវជំនួយហិរញ្ញវត្ថុដោយគ្មានពាក្យសុំផ្លូវការទេ។ ព័ត៌មានលម្អិតត្រូវបានគូសបញ្ជាក់នៅក្នុងគោលនយោបាយជំនួយហិរញ្ញវត្ថុ។

### ថ្លៃឈ្នួលដែលត្រូវបានគិតថ្លៃពីអ្នកជំងឺដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ
អ្នកជំងឺដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុនឹងមិនត្រូវបានរំពឹងទុកថានឹងបង់ថ្លៃសម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ឬការថែទាំដែលចាំបាច់ខាងផ្នែកវេជ្ជសាស្ត្រដទៃផ្សេងទៀតច្រើនជាងចំនួនដែលត្រូវបានចេញវិក្កយបត្រគិតថ្លៃជាទូទៅទៅឲ្យបុគ្គលដែលមានការធានារ៉ាប់រងលើការថែទាំបែបនេះឡើយ។

### ត្រៀមរួចរាល់ដើម្បីអនុវត្តជំហានបន្ទាប់ហើយមែនទេ?
បំពេញពាក្យសុំ ហើយដាក់បញ្ជូនវាទៅកាន់ផ្នែក Main Admitting (ទទួលជំងឺចូលធំ)។

គោលនយោបាយជំនួយហិរញ្ញវត្ថុ ពាក្យសុំ និងសេចក្តីសង្ខេបនេះមាននៅតាមគេហទំព័រ៖
http://www.chifranciscan.org/financialassistance ជាភាសាអង់គ្លេស និងអេស្ប៉ាញ និងភាសាដទៃផ្សេងទៀតចំនួនប្រាំពីរភាសា។ ដើម្បីទទួលបានច្បាប់ចម្លងដោយឥតគិតថ្លៃនៃឯកសារទាំងនេះតាមអ៊ីមែល ឬដោយផ្ទាល់
ដើម្បីទទួលបានជំនួយក្នុងការបំពេញពាក្យសុំ ឬដើម្បីស្នើសុំច្បាប់ចម្លងឥតគិតថ្លៃនៃឯកសារទាំងនេះដែលត្រូវបានបកប្រែទៅជាភាសាដែលមិនត្រូវបានពណ៌នារៀបរាប់មកនេះ សូមទាក់ទង៖

CHI Franciscan Rehabilitation Hospital
815 South Vassault Street
Tacoma, WA 98465
Phone: 253-444-3320
Fax: 253-444-3330

ឯកសារទាំងនេះក៏មានផងដែរនៅក្នុង Emergency Room (បន្ទប់សង្គ្រោះបន្ទាន់) និងតំបន់ Main Admitting (ទទួលជំងឺចូលធំ) នៃមន្ទីរពេទ្យ។